# សន្លឹកក្រដាសការណ៍ពិត លេខកូដម្ហូប #35

*អ្នកគួរតែដឹងអ្វីខ្លះ អំពីលេខកូដ*

WWW.HEALTHOREGON.ORG/FOODSAFETY

## ការចាក់ចោលទឹកសំណល់នៃរថលក់ម្ហូបចល័ត

**OAR 333-150-0000, ជំពូក 5-402.14**

**ការយកកាកសំណល់ ចេញពីគ្រឹះស្ថានរថលក់ម្ហូបចល័ត**

ទឹកស្អុយ ឬទឹកសំណល់ផ្សេងៗទៀត គួរតែបានយកចេញពីគ្រឹះស្ថានរថ លក់ម្ហូបចល័ត នៅឯតំបន់បំពីកាក សំណល់បានយល់ព្រម ឬដោយរថ យន្តដឹកជញ្ជូនទឹកស្អុយ ក្នុងរបៀប ដែលមិនគ្រោះថ្នាក់ដល់សុខភាព សាធារណៈ ឬមិនបង្កើតការសៅ ហ្មង។Pf
(A) រថលក់ម្ហូបចល័ត ដែលផលិត តែទឹកសំណល់ពណ៌ប្រផេះ អាចនឹង យួរទឹកសំណល់ទាំងនោះ ទៅកន្លែងចោលដាក់លាក់ បានយល់ព្រម ដោយអាជ្ញាធរដាក់បញ្ញត្តិ។
(B) ប្រដាប់ដាក់សំណល់ សំរាប់ដឹកជញ្ជូនត្រូវតែបានរៀបចំឡើង និងបានប៉ងដើម្បីផ្ទុក និងដឹកជញ្ជូន ទឹកពណ៌ប្រផេះ ដោយគ្មានការលេច ឬកំពប់ និងមាន ចំណុះធំជាង 20 ហ្កាឡុង។Pf

**មូលហេតុសុខភាព សាធារណៈ៖**

មានឧបសគ្គនៅទូទាំងរដ្ឋ ជាមួយវត្ថុមិនជាប់គ្នា នៅស្មៀមលើដីជុំវិញរថចល័ត បង្កើតឲ្យមានកន្លែងជាជំរកសត្វល្អិត និងសត្វកកេរ។ ដោយសារតែការនេះ យើងបានពង្រឹងការប្រតិបត្តិ សំរាប់ការបំពាន ទាំងនេះ ដោយមានការគាំទ្រពី សមាជិកនៃគណៈទីប្រឹក្សាវិន័យ។

លើសពីនេះទៀត ធុងទឹកមិនជាប់រថ បានក្លាយជាបញ្ហាសុខភាពសាធា រណៈ ដោយមានការកំពប់ទឹកសំណល់ និងការចាក់ទឹកចោល មិន ត្រឹមត្រូវ នៅលើកន្លែង ធ្វើឲ្យមាន ប្រឡាក់លូបង្ហូរទឹកភ្លៀង និងធ្វើឲ្យបឹង និងស្ទឹងកខ្វក់។

### សាវតារ

រថលក់ម្ហូបចល័តមួយចំនួន និងទូដែកចល័ត កំពុងតែប្រើធុងទឹកសំណល់ធំ នៅលើដី ដើម្បី ទុកទឹកសំណល់របស់គេ។

ការទុកធុងទឹកទាំងនេះនៅលើដី មិនដែលបាន អនុញ្ញាតក្នុងវិន័យទេ ហើយការប្រើរបស់គេ បាន បណ្ដាលឲ្យមានបញ្ហាជាមួយការកំពប់ លេច និងការផ្ដល់ទឹកឲ្យសត្វកកេរ និងសត្វចង្រៃ។



បន្ទាប់ពីការប្រឹក្សា ជាមួយអ្នកប្រើរថលក់ម្ហូបចល័ត, ដៃគូ និងអ្នកដាក់បញ្ញត្តិ, វិន័យអនាម័យម្ហូប ត្រូវបាន ពង្រឹង ដើម្បីអនុញ្ញាតសំរាប់ការប្រតិបត្តិ លើធុងទឹក ទាំងនេះដែលមិនបានយល់ព្រម។

**ពិគ្រោះជាមួយអ្នកត្រួតពិនិត្យរបស់អ្នក ជាប្រញាប់ ដើម្បីបង្កើតគំរោងការមួយ ដើម្បីប្រព្រឹត្តតាមវិន័យ ទាំងនេះ។ ឧទាហរណ៍នៃការប្រព្រឹត្តតាម គំរោងការគឺមាននៅ៖**

**https://www.oregon.gov/OHA/PH/HEALTHYENVIRONMENTS/FOODSAFETY/Pages/mobile.aspx**

### របៀបចាក់ចោល

មានជំរើសផ្សេងៗទូទាំងរដ្ឋ សំរាប់ការចាក់ចោល។ ឧទាហរណ៍ខ្លះៗ រួមមាន៖

- ការបើករថលក់ម្ហូបចល័តរបស់អ្នក ទៅកន្លែងចាក់ចោលបានយល់ព្រម។
- ការថែមធុងទឹកសំណល់ទីពីរ បាន តភ្ជាប់ទៅធុងទឹករបស់អ្នកមានស្រាប់ ដើម្បីបង្កើនចំណុះ។
- ការតភ្ជាប់ទៅប្រព័ន្ធចោលទឹកស្អុយ បានយល់ព្រម។
- ស្ថានីយចោល RV។
- ក្លាទឹកពូតប្រដាប់ជូត នៅក្នុងហាងទំនិញ របស់អ្នក មានអាជ្ញាប័ណ្ណ។
- ការបូមធុងទឹក ដោយអ្នកអូសមាន អាជ្ញាប័ណ្ណ។
- ការយួរទឹកសំណល់ ក្នុងធុងទឹក 20 ហ្កាឡុង បានរៀបចំឡើងដើម្បីផ្ទុក/ដឹក ជញ្ជូនទឹកពណ៌ប្រផេះ ដោយ គ្មានលេច ឬកំពប់។ ធុងជ័រ ឬប្រដាប់ដាក់ផ្សេងទៀត គឺមិនអនុញ្ញាតឡើយ។



***ប្រដាប់ដាក់យួរ មិនអាចនឹងហួសពីចំណុះ 20 ហ្កាឡុងឡើយ។ អ្នកប្រើអាចនឹងប្រើប្រដាប់ដាក់លើសពីមួយ បើសិនត្រូវការ ប៉ុន្តែ គេត្រូវតែបានចាក់ចោលរាល់ថ្ងៃ។***

**ការរកអ្នកដឹកជញ្ជូនមានអាជ្ញាប័ណ្ណ នៅក្នុងតំបន់របស់អ្នក៖**

https://www.deq.state.or.us/wq/onsite/sdssearch.asp

បើសិនអ្នកអូសបរិក្ខាររបស់អ្នក ផលិត សំពាធច្រើនពេក សំរាប់ធុងទឹកតូចៗ របស់អ្នក អ្នកអាចពិចារណារកប្រដាប់ដាក់តូច ដូចមួយនេះ ដើម្បីចាក់ចោលទឹកសំណល់របស់អ្នក ចូលទៅក្នុងវា អំឡុងពេលសប់ ប្រយោជន៍កុំឲ្យបាន បង្កើតខ្យល់៖



*ប្រភេទនៃប្រដាប់ដាក់នេះ ត្រូវតែអាច ផ្លាស់ប្តូរកន្លែងបានយ៉ាងងាយ និងអាចទុកនៅខាងក្នុងរថ នៅចុងបញ្ចប់នៃថ្ងៃ។*

**ទីកន្លែងសំរាប់ស្ថានីយចោលទឹកសំណល់ មាននៅពាសពេញរដ្ឋ Oregon ដែលធុងទឹកសំណល់ ជាប់នៅនឹងរថ និងប្រដាប់ដាក់យួរ អាចចាក់ចោលបាន៖**

https://www.rvdumps.com/category/dump-stations/?

https://rvshare.com/dumpstations/oregon

https://sanidumps.com/

https://www.campendium.com/oregon/dump-stations

ទីតាំងទាំងនេះគឺបានផ្តល់ឲ្យ សំរាប់ជួយអ្នកប្រើរថលក់ម្ហូបចល័ត ដើម្បីរកធនធាន ប៉ុន្តែមិនបានគាំទ្រ ឬបានយល់ព្រមដោយ OHA ឬដោយ LPHA តាមមូលដ្ឋាន របស់អ្នកឡើយ។

**ជំរើសផ្សេងៗទៀត៖**

ត្រូវឲ្យប្រាកដថាទទួលការយល់ព្រមមកពីអ្នកត្រួតពិនិត្យរបស់អ្នក មុននឹងចាក់ចោលទឹកសំណល់ នៅក្នុងកន្លែង ថ្មី។

*ដោយមានការអនុញ្ញាតមកពីម្ចាស់ និងអ្នកត្រួតពិនិត្យរបស់អ្នក អ្នកក៏អាចប្រើហាងលក់គ្រឿងឧបភោគបរិភោជនីយដ្ឋាន នៅក្បែរដែរ ឬនៅកន្លែងក្លាំទឹកពុតប្រដាប់ផូត មានអាជ្ញាប័ណ្ណផ្សេងទៀត ។*

*ធុងទឹកចោលទឹកសំណល់ មិនអាចនឹងទុកក្នុងរថយន្តផ្សេងទៀតបានទេ ដូចជានៅខាងក្រោយឡានត្រាក់ធំៗ។ ធុងទឹកទាំងអស់ដែលមិននៅជាប់រថ ត្រូវតែបានចាក់ចោល នៅចុងបញ្ចាប់នៃថ្ងៃនិមួយៗ។*